ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចព្រមព្រៀង

## រវាង

## ក្រុមហ៊ុន កាឡាខេម អ៊ិនវេសមេន ខូ អិលធីឌី ជាមួយប្រធានគ្រប់ផ្នែក

**កម្មវត្ថុ: ស្តីពីការ ព្យួរកិច្ចសន្យាការងារ កម្មករនិយោជិតចំនួន៦៥ នាក់រយៈពេល ៣៣ ថ្ងៃ**

**យោង**÷ កម្មវត្ថុខាងលើ ក្រុមហ៊ុន កាឡាខេម អ៊ិនវេសមេន ខូ អិលធីឌី និងប្រធានក្រុមគ្រប់ផ្នែកបានប្រជុំ ពិភាក្សាស្តីពីការព្យួរកិច្ចសន្យាការងារ កម្មករនិយោជិតចំនួន ៦៥ នាក់ រយៈពេល៣៣ថ្ងៃ

យោងកម្មវត្ថុខាងលើ និងដោយសារស្ថានភាព ក្រុមហ៊ុនយើងខ្ញុំខ្វះអ្នកបញ្ជាទិញ (ភ្ញៀវ Buyer)បានផ្អាក និងកាត់បន្ថយ នូវការទទួលនៅផលិត នៃការផលិតសម្រាប់ផលិតសម្លៀកបំពាក់។ ធ្វើអោយប៉ះពាល់ដល់ សង្វាក់ផលិតកម្ម។

ដូចនេះក្រុមហ៊ុន បានជួបពិភាក្សា និងប្រធានគ្រប់ក្រុម និងឆ្លងការពិគ្រោះយោបល់ និងបងប្អូន កម្មករ និយោជិត បានឯកភាពគ្នា យល់ព្រម ក្នុងការយោគយល់ នឹងអនុញ្ញាតអោយក្រុមហ៊ុន ធ្វើការព្យួរកិច្ចសន្យាការងារកម្មករនិយោជិតសរុបចំនួន ៦៥ នាក់ ស្រី ៥១ នាក់ ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន ១៦៦ នាក់ រយៈពេល ៣៣ ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០២២ រហូតដល់ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០២២ ។

ក្នុងរយៈពេលនៃការព្យួរកិច្ចសន្យាការងារ ក្រុមហ៊ុនបានព្រមព្រៀងគ្នា និងប្រធានគ្រប់ផ្នែក និងបងប្អូនកម្មករ និយោជិត ផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតចំនួន ៧០ ដុល្លារ នៃប្រាក់ឈ្នួល ១៩៤ ដុល្លារ អាមេរិក។

យោងតាមកម្មវត្ថុខាងលើ យើងខ្ញុំជា ប្រធានគ្រប់ក្រុម និងបងប្អូនកម្មករនិយោជិតចំនួន ៦៥ នាក់ បានឯកភាពគ្នាយល់ព្រម និងផ្តល់តំណាង ផ្តិតម្រាមដៃ ជាសាក្សី ជាអំណះអំណាង ភស្តុតាង យល់ព្រមទទួលយក និងការព្យួរកិច្ចសន្យាការងាររយៈពេល ៣៣ ថ្ងៃ និងប្រាក់ឧបត្ថម្ភជូនកម្មករនិយោជិតចំនួន ៧០ ដុល្លារ នៃប្រាក់ឈ្នួល ១៩៤ ដុល្លារអាមេរិក។

អាស្រ័យហេតុដូច កិច្ចសន្យាព្រមព្រៀងខាងលើ យើងខ្ញុំទាំងអស់គ្នា យល់ព្រមទទួលខុសត្រូវចំពោះមុខច្បាប់ ដោយមិនផ្តល់បញ្ហាអោយក្រុមហ៊ុនជួបការលំបាកនោះឡើយ។

ថ្ងៃព្រហស្បតិ៍ ០៤ កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព ស ២៥៦៦

កំពង់ស្ពឺ ត្រូវនឹង ថ្ងៃទី ២៩ ខែសីហា ឆ្នាំ ២០២២

ហត្ថលេខា និងត្រា នាយក ឬរដ្ឋបាល

CALACAM INVESTMENT CO.,LTD.

ហត្ថលេខា និង ស្នាមម្រាមដៃ

ក. ប្រធានរដ្ឋបាល

ខ. តំណាងកម្មករ

គ. ប្រធានក្រុមគ្រប់ផ្នែក